**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៥-០៩-១៦៤ ប្រ.ក

# ប្រកាស
## ស្ដីពី
## ការបង្កើតគណៈកម្មការប្រតិបត្តិ រៀបចំទីផ្សារអន្តរធនាគារ និងប្ដូរប្រាក់

**ទេសាភិបាល ធនាគារជាតិនៃកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើ ច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មមាត្រា១៤ និងមាត្រា៥៧ នៃច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៨៩៧/០៣ ចុះថ្ងៃទី ២២ ខែសីហា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការគ្រប់គ្រងការប្ដូរប្រាក់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៨/៥២៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ស្ដីពីការតែងតាំង ឯកឧត្ដម **ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា មានឋានៈស្មើទេសរដ្ឋមន្ត្រី
- យោងតាមការសំរេចរបស់អង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៩

## ស ម្រេ ច

**ប្រការ ១.–**

បង្កើតគណៈកម្មការប្រតិបត្តិ រៀបចំទីផ្សារអន្តរធនាគារ និងប្ដូរប្រាក់ ដែលមានសមាសភាពដូចខាង ក្រោម :

| | | |
|---|---|---|
| ១. លោកជំទាវ តាល់ ណៃអ៊ីម | អគ្គនាយក | ប្រធាន |

| | | | |
|---|---|---|---|
| ២. | លោកស្រី ង៉ូន សុខា | អគ្គនាយករង | អនុប្រធាន |
| ៣. | លោកស្រី គាំ គណ្ឋា | ប្រធាននាយកដ្ឋានប្រតិបត្តិការ | សមាជិក |
| ៤. | លោកស្រី ស្រី ស៊ីយុត | ប្រធាននាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់ | សមាជិក |
| ៥. | លោក អ៊ូ ចាន់តារ៉ា | ប្រធាននាយកដ្ឋានគណនេយ្យ | សមាជិក ។ |

**ប្រការ ២.—**

គណៈកម្មការប្រតិបត្តិ គ្រប់គ្រងទីផ្សារអន្តរធនាគារ និងប្តូរប្រាក់ មានមុខងារភារកិច្ច ដូចតទៅ :

- រៀបចំបទបញ្ញាសម្រាប់មូលប័ត្ររបស់ធនាគារជាតិនៃកម្ពុជា
- រៀបចំគំរូកិច្ចសន្យាប្រតិបត្តិការទិញយកវិញ
- រៀបចំប្រព័ន្ធទូទាត់ និង ការប្រគល់និងការទូទាត់សង
- រៀបចំសេវាគ្រប់គ្រង រក្សាទុកនូវមូលប័ត្ររបស់ធនាគារជាតិនៃកម្ពុជា
- ដោះស្រាយបញ្ហាគណនេយ្យ និងរៀបចំក្រុមគ្រប់គ្រងប្រតិបត្តិលើដំណើរការមូលប័ត្រ
- រៀបចំបង្កើតគោលនយោបាយ និងនីតិវិធីផ្ទៃក្នុងដែលចាំបាច់ និងរៀបចំរចនាសម្ព័ន្ធការងារ ដើម្បីប្រសិទ្ធភាពនៃការអនុវត្ត
- តាមដានការវិវត្តមុខងារ ភារកិច្ចនាពេលអនាគត និងសម្របសម្រួលជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីចេញផ្សាយ និងផ្តល់សេវាគ្រប់គ្រងរក្សាទុក មូលប័ត្រអាចជួញដូរបាន និង សញ្ញាប័ណ្ណ របស់រដ្ឋាភិបាល
- តាមដាន និងដោះស្រាយបញ្ហាដែលកើតមានឡើង និងដែលមានផលប៉ះពាល់ដល់ការគ្រប់គ្រងសាច់ប្រាក់ងាយស្រួល ការបង្កើនប្រសិទ្ធភាព និងការអនុវត្តគោលនយោបាយរូបិយវត្ថុ របស់ធនាគារជាតិនៃកម្ពុជា ។

**ប្រការ ៣.—**

គណៈកម្មការប្រតិបត្តិ រៀបចំទីផ្សារអន្តរធនាគារ និងប្តូរប្រាក់ត្រូវប្រជុំជាទៀងរាល់សប្តាហ៍ និងអាចកោះប្រជុំនៅពេលណាក៏បានតាមការចាំបាច់ ។

**ប្រការ ៤.—**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តនូវខ្លឹមសារនៃប្រកាសនេះតាមភារកិច្ចរៀង១ខ្លួនឱ្យមានប្រសិទ្ធភាពខ្ពស់ ។

**ប្រការ ៥.—**

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។ ៚

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែ មិថុនា ឆ្នាំ ២០០៩

**ទេសាភិបាល**

**ជា-ចាន់តូ**

**កន្លែងទទួល**
- ដូចប្រការ ៤ " ដើម្បីអនុវត្ត "
- កាលប្បវត្តិ
- ឯកសារ

**ចម្លងជូន**
- សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាបជាព័ត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"